ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation - Religion - King*

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
លេខ...៧៤៨/១០.....ក.អ.ក / គ.ជ.នា

រាជធានីភ្នំពេញ.ថ្ងៃទី...០៩.......ខែ.មិថុនា...ឆ្នាំ២០១០

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : របាយការណ៍បញ្ចប់ស្តីពីការរៀបចំនិងលទ្ធផលនៃវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

**យោង** : សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៧៤ ស.ស.រ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងដំណើរការវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

ឯកសារភ្ជាប់ : - តារាងសូចនាករតាមដានរួមគ្នា ២០១០-២០១១

- តារាងក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំសម្រាប់ឆ្នាំ២០១០-២០១២

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ និងផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាលដែលបានប្រគល់ភារកិច្ចឱ្យខ្ញុំ និងបណ្ឌិត **អ៊ូន ព័ន្ធមុនីរ័ត្ន** ព្រមទាំងឯកឧត្តម **ឈៀង យ៉ាណារ៉ា** សម្រាប់សម្របសម្រួលការរៀបចំ និងដឹកនាំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ នាថ្ងៃទី២- ៣ ខែមិថុនា ឆ្នាំ២០១០ នៅវិមានរដ្ឋាភិបាល ខ្ញុំសូមគោរពរាយការណ៍អំពីការរៀបចំ និងលទ្ធផលគន្លឹះនៃវេទិកាជូន **សម្តេច នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ដូចតទៅ ÷

I- កិច្ចដំណើរការ : វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ បានប្រារព្ធទៅនាថ្ងៃទី២- ៣ ខែមិថុនា ឆ្នាំ២០១០ ប្រកបដោយជោគជ័យ ។ **សម្តេចនាយករដ្ឋមន្ត្រី** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានអញ្ជើញជាអធិបតីក្នុងពិធីបើកវេទិកា និងបានថ្លែងសុន្ទរកថាគន្លឹះ ព្រមទាំងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ សម្រាប់ជាទុនកុសលដល់កិច្ចពិភាក្សានៃវេទិកា ។ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងឯកឧត្តមជាសមាជិក សមាជិការាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីជំនាញជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ ជាឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រធានស្ថាប័នតំណាងប្រទេសនិងស្ថាប័នដៃគូអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី ព្រមទាំងមន្ត្រីជាន់ខ្ពស់ដែលបានអញ្ជើញមកពីស្នាក់ការកណ្តាលសរុបជាង២៥០រូប បានចូលរួមក្នុងវេទិកាលើកនេះ ។

ការត្រៀមរៀបចំនានា ទាំងខាងបច្ចេកទេស ទាំងផ្នែកប្រព័ន្ធផ្តល់ការសម្របសម្រួលសម្រាប់ដំណើរការវេទិកា (Technical and Logistic Arrangements) ស្ថិតក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) ដែលទទួលបន្ទុកជាអគ្គលេខាធិការដ្ឋាននៃវេទិកា ។ ជំហានការងារដែលបានអនុវត្ត រួមទាំងការរៀបចំឯកសារសំយោគរបស់រាជរដ្ឋាភិបាល ត្រូវបានពិភាក្សា និងឯកភាពជា



វិមានរដ្ឋាភិបាល. វិថីស៊ីសុវត្ថិ.វត្តភ្នំ.ភ្នំពេញ.ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ ទូរសារ: (៨៥៥) ២៣-៩៨១ ០២៧ . ៩៩៨ ៩៨០ . ៩៨១ ១៥៨
Government Palace. Sisowath Quay. Wat Phnom Phnom Penh, Cambodia.
Tel / Fax(855)23981 027/ 998 980/ 981 158

គោលការណ៍ជាមួយនឹងក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយបន្ទាប់មក ត្រូវបានពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ តាមរយៈលោក Qimiao Fan នាយកធនាគារពិភពលោកនៅកម្ពុជា ក្នុងឋានៈជាអ្នកសម្របសម្រួលដែលជ្រើសតាំងដោយដៃគូអភិវឌ្ឍន៍សម្រាប់វេទិកាលើកនេះ ហើយចុងក្រោយបង្អស់ ត្រូវបានពិភាក្សានិងឯកភាពនៅក្នុងកិច្ចប្រជុំលើកទី១៦របស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ ។ ក្នុងការសម្របសម្រួលនិងត្រៀមរៀបចំវេទិកា គ.ជ.ន/ក.អ.ក បានប្រើប្រាស់ «យន្តការក្រុមការងារបច្ចេកទេស ចម្រុះ» យ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាព ។ ពិសេស រាល់មតិយោបល់ ឬសំណើកែសម្រួលទាំងឡាយដែលលើកឡើងដោយស្ថាប័នរាជរដ្ឋាភិបាល ឬដោយដៃគូអភិវឌ្ឍន៍ ត្រូវបានពិភាក្សាយ៉ាងម៉ត់ចត់នៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ និងឯកភាពដោយប្រធានក្រុមការងារបច្ចេក-ទេសចម្រុះ ។ តាមចំណាត់ការបែបនេះ រាជរដ្ឋាភិបាលបានធានាភាពជាម្ចាស់របស់តាមរយៈក្រុមការងារបច្ចេក-ទេសចម្រុះ និងបានពង្រឹងគណនេយ្យភាពទ្វេទិស ។ ក្នុងស្មារតីនេះ ខ្ញុំសូមវាយតម្លៃខ្ពស់នូវការចូលរួមដោយផ្ទាល់របស់ឯកឧត្តម លោកជំទាវ ជាប្រធានស្ថាប័ន និងប្រធានក្រុមការងារបច្ចេកទេសចម្រុះនៅក្នុងដំណើរការនេះ ។ ការប្រព្រឹត្តិទៅដោយរលូន និងលទ្ធផលជាក់ស្តែងរបស់វេទិកា បានឆ្លុះបញ្ចាំងអំពីភាពជាម្ចាស់យ៉ាងរឹងមាំរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ និងដឹកនាំវេទិកាលើកនេះ ។

II- <u>លទ្ធផលគន្លឹះ</u> : អង្គវេទិកាបានដំណើរការតាមរបៀបវារៈដែលបានគ្រោងទុក ។ សុន្ទរកថាគន្លឹះ និងអានុសាសន៍ដ៏ខ្លង់ខ្លស់របស់ **សម្តេច តេជោនាយករដ្ឋមន្ត្រី** នៅក្នុងឱកាសបើកវេទិកា បានផ្តល់ជាមគ្គុទេសសម្រាប់ពិភាក្សានិងផ្លាស់ប្តូរយោបល់តាមរបៀបវារៈនីមួយៗ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ក៏បានធ្វើបទឧទ្ទេសនាម និងបានស្រាយបំភ្លឺបញ្ហានានាដែលពាក់ព័ន្ធនឹងរបៀបវារៈស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ រួមទាំងការប្រឆាំងអំពើពុករលួយផងដែរ ។ ពិនិត្យជារួម តាមរបៀបវារៈនីមួយៗនៃវេទិកា រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នាលើការវាយតម្លៃពីវឌ្ឍនភាពនៅតាមការដ្ឋានកំណែទម្រង់សំខាន់ៗ បញ្ហាប្រឈមគន្លឹះ និងទិសដៅអាទិភាពដែលបានឯកភាពគ្នាសម្រាប់អនុវត្តបន្ត ។ ខ្ញុំសូមអនុញ្ញាតរំលេចលទ្ធផលគន្លឹះដែលបានឯកភាពរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដូចខាងក្រោម ÷

ក- <u>តួនាទីរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម</u> : វេទិកាបានឯកភាពថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ជាមូលដ្ឋានគ្រឹះនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្ត **«យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២»** ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។ វេទិកាបានឯកភាពថា ឆន្ទៈ និងការប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាល គឺជាកត្តាកំណត់សំខាន់បំផុតក្នុងការអនុវត្តន៍ប្រកបដោយជោគជ័យ នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម ។ ជំហានការងារបន្ទាប់ គឺការរៀបចំបញ្ចប់នូវតារាងសូចនាករសំខាន់ៗ និងក្របខ័ណ្ឌសម្រាប់តាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងកិច្ចប្រឹងប្រែងឱ្យមានវឌ្ឍនភាពក្នុងការធ្វើសុខដុមនីយកម្ម រវាងការងារផែនការ និងចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។

ខ- <u>ការអនុវត្តន៍កម្មវិធីកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាលដោយមានសម្របសម្រួលជាមួយគ្នា</u> : វេទិកាបានយល់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តមោះមុតរបស់រាជរដ្ឋាភិបាល ពិសេសតាមរយៈសារនយោបាយគន្លឹះ ប្រកបដោយឆន្ទៈមោះមុតរបស់ **សម្តេច តេជោនាយករដ្ឋមន្ត្រី** នាពេលបើកវេទិកា ក្នុងការបន្តអនុវត្តន៍បណ្តាកម្មវិធីកំណែទម្រង់ ដូចជាកំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ការប្រឆាំងអំពើពុករលួយ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដទៃទៀត ។ លើសពីនេះ វេទិកាក៏បានឯកភាពអំពីសារៈសំខាន់ និងភាពចាំបាច់ក្នុងការអនុវត្តន៍កម្មវិធីកែទម្រង់ទាំងនេះដោយមានការសម្របសម្រួល ដើម្បីធានាឱ្យមានសង្គតិភាពនៅតាមការដ្ឋានកំណែទម្រង់នីមួយៗ និងការគាំទ្រឱ្យគ្នាទៅវិញទៅមករវាងការដ្ឋានកំណែទម្រង់មួយទៅការដ្ឋានកំណែទម្រង់មួយទៀត និងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ក្នុងស្មារតីនេះ យន្តការក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នឹងបំពេញតួនាទីកាន់តែសំខាន់ និងប្រកបដោយប្រសិទ្ធភាពថែមទៀតនៅក្នុងកិច្ចការទាំងនេះ ។

គ- <u>សូចនាករតាមដានរួមគ្នា</u> (Joint Monitoring Indicators) : វេទិកាលើកទី៣ បានឯកភាពលើតារាងសូចនាករតាមដានរួមគ្នា ដូចមានជូនភ្ជាប់មកជាមួយនេះ ។ សូចនាករតាមដានរួមគ្នាដែលបានឯកភាពនឹងត្រូវអនុវត្ត និងតាមដានរួមគ្នាដោយរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ចាប់ពីវេទិកាលើកនេះរហូតដល់វេទិកាលើកបន្ទាប់ទៀត ។ កិច្ចដំណើរការ គិតចាប់តាំងពីការរៀបចំស្នើសូចនាករតាមដានរួមគ្នាដោយក្រុមការងារបច្ចេកទេសចម្រុះ តាមរយៈការពិភាក្សានិងឯកភាពជាមួយដៃគូពាក់ព័ន្ធ ទាំងនៅកម្រិតក្រុមការងារ និងនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ រហូតឈានដល់ការឯកភាពគ្នានៅក្នុងវេទិកាលើកនេះ បានប្រព្រឹត្តទៅដោយរលូន និងស្ថិតក្រោមបរិការនៃភាពជាម្ចាស់យ៉ាងពេញលេញរបស់រាជរដ្ឋាភិបាល ។ សូចនាករតាមដានរួមគ្នាដែលបានឯកភាពនេះ បានសង្កត់លើវិធីសាស្ត្រវាយតម្លៃការងារដោយផ្អែកលើលទ្ធផល និងយន្តការត្រួតពិនិត្យរួមគ្នា ។

ឃ- <u>ក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ</u> : ដៃគូអភិវឌ្ឍន៍ទាំងអស់បានប្រកាសតួលេខណែនាំស្តីពីការគាំទ្រហិរញ្ញប្បទានសម្រាប់ឆ្នាំ២០១០-២០១២ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ (Multi Year Indicative Financing Framework) ។ គិតតាមតួលេខដែលបានប្រកាសនៅក្នុងវេទិកា រាជរដ្ឋាភិបាលបានកៀរគរធនធានចំនួន ១.០៩៧លានដុល្លាអាមេរិក សម្រាប់ឆ្នាំ២០១០ និងចំនួន២.៨០៥ លានដុល្លាអាមេរិក សម្រាប់រយៈពេល៣ឆ្នាំ២០១០-២០១២ ។ ដូចនេះ រាជរដ្ឋាភិបាលមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តគោលដៅយុទ្ធសាស្ត្រនានានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ- បច្ចុប្បន្នកម្ម សម្រាប់ឆ្នាំ២០១០ ។ ខ្ញុំសូម ភ្ជាប់មកជាមួយនូវតារាងលំអិតនៃហិរញ្ញប្បទានពហុឆ្នាំដែលដៃគូអភិវឌ្ឍន៍បានប្រកាសនៅក្នុងវេទិកា ។ ការងារដែលក្រសួង និងស្ថាប័នត្រូវអនុវត្តបន្ត ពិសេស ក.អ.ក/គ.ជ.នា គឺការចរចាជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីប្រែក្លាយការប្រកាសផ្តល់ធនធាននេះ ឱ្យទៅជាគម្រោងអនុវត្តជាក់ស្តែង និងការប្រើប្រាស់ធនធានទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ សម្រាប់អនុវត្តបណ្តាគោលដៅអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

ស្ថាប័នត្រូវអនុវត្តបន្ត ពិសេស ក.អ.ក/គ.ជ.នា គឺការចរចាជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីប្រែក្លាយការប្រកាសផ្តល់ធនធាននេះ ឱ្យទៅជាគម្រោងអនុវត្តជាក់ស្តែង និងការប្រើប្រាស់ធនធានទាំងនេះឱ្យមានប្រសិទ្ធភាពខ្ពស់សម្រាប់អនុវត្តបណ្តាគោលដៅអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **សម្តេច នាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាវបាយការណ៍ដ៏ខ្ពង់ខ្ពស់តាមការគួរ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ប្រធានវេទិកាលើកទី៣**

**គាត ឈន់**

<u>ចម្លងជូន</u> :

- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ឯកសារ

10. 6. 10